# កំណត់ត្រារបស់នាយក

ដោយ បណ្ឌិត ហ្វីលីព ប៊ីកាំ

ពេលចុងឆ្នាំ ២០០១ នេះ ត្រូវនឹងខួបបីឆ្នាំ ដែលមជ្ឈមណ្ឌលខេមរសិក្សាយើង ចាប់សាងសង់ក្នុងទ្រង់ទ្រាយជាស្ថាប័ន ។ នៅពេលចុងឆ្នាំនេះ យើងក៏នៅតែមានការខិតខំព្យាយាមទ្វេឡើង ដើម្បីពង្រឹងការទទួលស្គាល់នូវតម្លៃដែលយើងបានសង់នៅលើជោគជ័យរបស់សិក្ខាសាលាយើង នាខែមករា ២០០១ កន្លងមកនេះ ។

ក្រុមរបស់ ម.ខ.ស. បានយកចិត្តទុកដាក់ចំពោះគោលដៅសំខាន់ ៣ ដូចតទៅនេះ ៖

_ការចាប់ផ្តើមប្រតិបត្តិការរបស់មជ្ឈមណ្ឌលយើង

_ការពង្រឹងក្រុម និងការគ្រប់គ្រងផ្ទៃក្នុងរបស់មជ្ឈមណ្ឌលឲ្យកាន់តែល្អឡើង

_ការស្វែងរកនូវសេចក្តីទទួលស្គាល់របស់ ម.ខ.ស. ទូទាំងប្រទេសកម្ពុជា ក៏ដូចជានៅក្រៅប្រទេស ។

*ការចាប់ផ្តើមប្រតិបត្តិការរបស់ ម.ខ.ស.*

សកម្មភាពរបស់ ម.ខ.ស. មាន ការសំដៅ ជាអាទិ៍ ទៅលើការទ្រទ្រង់កម្មវិធីជាចម្បងឲ្យមានដំណើរការល្អ ។ កម្មវិធីនេះ មានការពាក់ព័ន្ធទៅនឹងបណ្ណាល័យ សាលសន្និសីទ ផ្ទះសម្រាប់ស្នាក់នៅ ហើយនឹងផ្នែកបោះពុម្ព (គឺ ព្រឹត្តិប័ត្រ និងវិបសាយថ៍) ។ ក្នុងកំណត់ត្រានេះ ខ្ញុំបានសម្រេចចិត្តលើកកម្មវិធីទាំងនេះ មកបង្ហាញ ពីព្រោះវាជាផ្នែកសំខាន់របស់មជ្ឈមណ្ឌល ។

ដោយសារការព្យាយាមដ៏ហ្មត់ចត់របស់ចាងហ្វាងបណ្ណាល័យ និងជំនួយការរបស់ចាងហ្វាង គឺលោក ឆេង ផារីន និងអ្នកស្រី អ៊ុំ ដារាណែត បណ្ណាល័យបានក្លាយទៅជាកន្លែងតម្កល់ទុកឯកសារមានចំនួនច្រើន ជា ៣ ភាសា ថែមទាំងបានក្លាយទៅជាកន្លែងដ៏មានសភាពរស់រវើក ដោយហេតុថា អ្នកសៀមរាបជាច្រើនចូលមកបណ្ណាល័យ ។

ជោគជ័យដ៏តូចតាចទាំងឡាយ ដែលពាក់ព័ន្ធនឹងដំណើរការរបស់បណ្ណាល័យ ខ្ញុំពុំអាចរៀបរាប់នៅទីនេះបានទេ តែមនុស្សដែលមកអានសៀវភៅ មកពីគ្រប់ស្រទាប់នៃប្រជាជនសៀមរាប គឺមានទាំងលោកសង្ឃ គ្រូបង្រៀននិងសិស្សវិទ្យាល័យ មគ្គុទេសក៏ទេសចរ ភ្ញៀវបរទេស និង អ្នកស្រុកដែលមកបណ្តុះបណ្តាលអង្គឯងនិងខ្លួនឯង ។ ដោយហេតុនេះ បានជាអ្នកអាន និងអ្នកស្រាវជ្រាវសញ្ជាតិកម្ពុជា មានឱកាសទាក់ទងនឹងជនបរទេស ។ មនុស្សណាដែលពីមុនមក ពុំសូវជឿថា ថ្ងៃណាមួយ មហាជននៅសៀមរាបនឹងមានបណ្ណាល័យដែលមានសៀវភៅប្រកបដោយចំណេះវិទ្យា ក៏ស្រាប់តែមានការងឿងឆ្ងល់យ៉ាងខ្លាំង ។ ហើយខ្ញុំឯងសូមសារភាពថា ពេលដំបូង ខ្ញុំក៏មិនសូវមានការទុកចិត្តទៅលើជោគជ័យនៃបណ្ណាល័យយើងប៉ុន្មានដែរ ។

ពួកយើងខ្ញុំមានបំណងចង់បន្តសកម្មភាព និងការពង្រីកបណ្ណាល័យយ៉ាងនេះ ដោយសារ យើងជឿជាក់ថា បណ្ណាល័យនៃ ម.ខ.ស. ក៏មានសារៈសំខាន់ សម្រាប់បេសកកម្ម ម.ខ.ស. ដូច *សិក្សាចក្រ* និងវិបសាយថ៍ដែរ ក្នុងការផ្តល់សេវាសាធារណៈ ។

សព្វថ្ងៃនេះ គឺសុទ្ធសឹងតែសប្បុរសជនដ៏មានចិត្តសទ្ធាជ្រះថ្លា ដែលជួយ ឧបត្ថម្ភបណ្ណាល័យ ម.ខ.ស. ។ អ្នកខ្លះបានធ្វើអំណោយសៀវភៅតែ ១ ក្បាល តែដែលប្រកបដោយខ្លឹមសារដ៏សំខាន់បំផុត អ្នកខ្លះទៀត បានធ្វើអំណោយឈុតសៀវភៅ ដែលមានគ្រប់ក្បាលគ្រប់ភាគទាំងអស់ ឬក៏បានធ្វើអំណោយជាប្រាក់ដើម្បីជាវសៀវភៅ ។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់សប្បុរសជនទាំងអស់នេះដែលជួយធ្វើឲ្យបណ្ណាល័យកាន់តែរុងរឿង ហើយខ្ញុំសូមស្វាគមន៏អ្នកណាដែលប៉ងជួយក្នុងរឿងនេះ ។

ព្រឹត្តិប័ត្ររបស់មជ្ឈមណ្ឌល គឺ *សិក្សាចក្រ* នេះឯង ក៏ជាផ្នែកសំខាន់ នៃមជ្ឈមណ្ឌលយើង ។ លោក មីស្ហែល ឬទ្ធី អង់តែល្ម ដែលជាអ្នកបង្កើត *សិក្សាចក្រ* រយៈពេល ២ ឆ្នាំមកហើយ និងរហូតដល់បច្ចុប្បន្ននេះ *សិក្សាចក្រ* នៅតែចេញ ២ លើកក្នុង ១ ឆ្នាំ ។ ។ ម្យ៉ាងទៀត ព្រឹត្តិប័ត្រនេះ ក៏បានសម្រេចទៅជាវេទិកាដ៏ល្បីល្បាញ សម្រាប់ប្រយោជន៏អ្នកស្រាវជ្រាវ អ្នកសិក្សា និងអ្នកឯទៀត ។ ដែលមានចំណាប់អារម្មណ៏ទៅលើខេមរសិក្សា ។ យើងខ្ញុំអរណាស់ដោយឃើញថា អ្នកស្រាវជ្រាវ មានការចាប់ចិត្តចេះតែកើនឡើង ហើយចេះតែផ្ញើអត្ថបទស្រាវជ្រាវរបស់ខ្លួន ដើម្បីឲ្យបោះពុម្ពផ្សាយ ។

យើងខ្ញុំកំពុងតែសាងសង់វត្តមាន ដែលគេអាចគិតថា ពុំសូវមានភាពជាក់ស្តែង តែដែលមានសារៈសំខាន់ណាស់ គឺនៅក្នុងអ៊ិនធឺរណេត ដែលយើងបានចាប់ផ្តើមសាងសង់ឡើងតាំងពីខេត្តសៀមរាប ពុំទាន់មានគមនាគមន៏សក្តិសិទ្ធិតាម អ៊ិនធឺរណេតម្ល៉េះ (តែឥឡូវនេះស្ថានភាពនេះ កាន់តែប្រសើរឡើងយ៉ាងឆាប់រហ័ស) ។ ដោយសារសកម្មភាពដំបូងរបស់ អ្នកស្រី អាឡេស្សណ្ត្រា គីម នៅក្រុងញីវយ៉ក រួចហើយរបស់ លោក ដាញ់ ហុង និងលោក ចន វីក្ស ឥឡូវនេះ ម.ខ.ស. មានវិបសាយថ៍ជា ៣ ភាសា ដែលបង្ហាញនូវមជ្ឈមណ្ឌល និងសកម្មភាពរបស់មជ្ឈមណ្ឌល ។ ការផ្សាយក្នុងអ៊ិនធឺរណេតជាភាសាខ្មែរ ប្រកបដោយការលំបាកផ្នែកបញ្ញវន្ត និងផ្នែកបច្ចេកទេស ជាបញ្ហាដ៏សាំញ៉ាំបំផុត ដែលគួតែដោះស្រាយ ។

*សិក្សាចក្រ* និងវិបសាយថ៍ (http://www.khmerstudies.org) ចេះតែជួយផ្សព្វផ្សាយយ៉ាងកើនឡើង នូវសកម្មភាពស្រាវជ្រាវ ដែលបានធ្វើដោយមានសហការជាមួយមជ្ឈមណ្ឌលយើង និងជួយលើកតម្កើងសកម្មភាពរបស់ស្ថាប័នដែលជាសមាជិកក្នុងក្រុមគ្រប់គ្រង ម.ខ.ស. ។ *សិក្សាចក្រ* និងវិបសាយថ៍ជាផ្លូវឯកជា ៣ ភាសា សម្រាប់ភ្ជាប់ភ្ជុំអ្នកប្រាជ្ញ មកពីប្រទេស វិស័យសិក្សា និងតំណ ផ្សេងគ្នា ។

ពិតមែនហើយ យើងត្រូវតែធ្វើអ្វី ។ ឲ្យបានច្រើនជាងនេះទៅទៀតក្នុងផ្នែកផ្សព្វផ្សាយ ផ្នែកផ្ញើសំបុត្រនិងសារ និងផ្នែកបកប្រែ ។ ដូចជាបណ្ណាល័យ ដែល *សិក្សាចក្រ* និងវិបសាយថ៍ របស់ ម.ខ.ស. ត្រូវការការជួយឧបត្ថម្ភ ដើម្បីឲ្យ អាចបន្តការជូនសេវា និងការពង្រីកសេវាជានិច្ចសម្រាប់សហគមន៏ខេមរវិទ្យា ។ សម្រាប់ប្រយោជន៏

គម្រោងការ ២ នេះ មជ្ឈមណ្ឌលយើងបានទទួលជំនួយជាប្រាក់ពីមូលនិធិ វ៉ាន់ វើរ៉ុីន ដែលស្ថិតនៅក្រុងញីវយ៉ក ។

សកម្មភាពដ៏សំខាន់ ៗ ដែលមជ្ឈមណ្ឌលចង់ចម្រើនក្នុងពេលឆាប់ ៗ នេះ គឺសាលសន្និសីទ ការសង់អគារ និងការរកផ្ទះសម្រាប់ស្នាក់នៅ ។

ដើម្បីរក្សាបេសកកម្មខាងសេវាសាធារណៈរបស់យើង យើងខ្ញុំកំពុងពង្រីកសាលសន្និសីទធ្វើជាកន្លែងសាធារណៈ សម្រាប់ការអប់រំនិងសិល្បៈ ។ ក្នុងឆ្នាំ ២០០២ នេះ យើងមានគម្រោងដ៏ធំ ១ ដែលចង់បើកឲ្យមានការប្រជុំសិក្សា ការតាំងពិព័រណ៍ និងការសម្ដែងសិល្បៈ ។

ជាពិសេសទៅទៀត យើងនឹងធ្វើសិក្ខាសាលាស្ដីអំពីការសិក្សាសម័យមុនអង្គរ ១ សិក្ខាសាលាអំពីសិល្បៈសម្ដែង ១ ហើយនិងសិក្ខាសាលាអំពីស្ថាបត្យកម្មក្នុងស្រុក ១ ។ ក្នុងខែមករា ២០០៣ យើងនឹងធ្វើសិក្ខាសាលាអំពីខេមរវិទ្យា ដែលយើងធ្វើ ២ ឆ្នាំ ម្ដង ។

គម្រោងការ ១ ក្នុងចំណោមគម្រោងការរបស់យើង ដែលមិនសូវមានសភាពជាក់ស្ដែងនិងធំដុំទាំងប៉ុន្មាន (តែដែលមានសារៈសំខាន់ដែរ) គឺការរកបានផ្ទះ ២ ខ្នង សម្រាប់ស្នាក់នៅ ១ ខ្នង នៅសៀមរាប ១ ខ្នងទៀត នៅភ្នំពេញ ។ ផ្ទះនេះ នឹងចែកជូនបុគ្គលិកសាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងមិត្តភក្តិរបស់មជ្ឈមណ្ឌល ហើយសព្វថ្ងៃនេះ សមាជិករបស់មជ្ឈមណ្ឌល ២ នាក់ កំពុងស្នាក់នៅទីនោះ ។ ការមានផ្ទះទាំងនេះ នឹងជួយដល់ភ្ញៀវរបស់យើង កុំឲ្យខាតពេល ក្នុងការរៀនយល់អំពីប្រទេសខ្មែរ ។ ម្យ៉ាងវិញទៀត វាជាឱកាសដ៏ល្អមួយ ដែលធ្វើឲ្យកើតមាននូវនិច្ច័យសហាគមន៍រវាងមនុស្សទាំងឡាយ ដែលមានការពាក់ព័ន្ធមកនឹងមជ្ឈមណ្ឌលយើង ។

បុគ្គលិកដែលជាភ្ញៀវ (តាមធម្មតា អញ្ជើញមកពីសាកលវិទ្យាល័យ ដែលរួមការងារជាមួយយើង) បានឆ្លៀតមកស្នាក់នៅផ្ទះនេះ ហើយផ្ទះដែលនៅភ្នំពេញ ក៏សម្រាប់ធ្វើជាការិយាល័យសម្រាប់អ្នកស្រាវជ្រាវដែលមកក្នុងកម្មវិធីរួមរបស់ ម.ខ.ស. និងមូលនិធិ រ៉ុកឺហ្វេល្ល័រ ។

ក្រៅពីនេះ មជ្ឈមណ្ឌលក៏ប្រតិបត្តិធ្វើកម្មវិធីសិក្សាដែលមានចំនួនកាន់តែកើនឡើង ។ កម្មវិធីអស់នេះ គេបានស្នើបង្កើតអំពីអនុសាសន៍នៃសិក្ខាសាលាខែមករា ២០០១ ហើយនេះអាចធ្វើបានដោយសារការចាប់អារម្មណ៍ និងការគាំទ្ររបស់មូលនិធិចំនួនច្រើន ។

ការល្បងពិសោធធ្ងន់ ១ សម្រាប់យើង គឺការកំណត់របៀបរបប និងលក្ខណៈផ្ទាល់នៃកម្មវិធីសិក្សារបស់មជ្ឈមណ្ឌល ដែលត្រូវពឹងផ្អែកទៅលើបេសកកម្មត្រីភាគីរបស់យើង គឺ ការស្រាវជ្រាវ ការបង្រៀន និងសេវាសាធារណៈ ព្រមទាំងការយកចិត្តទុកដាក់ក្នុងការរួមបញ្ចូលទាំងគេទាំងឯង ។ នៅក្នុងលេខនេះ លោក ហ្វ្រង់ស្វា តាំងទុយរីយ៉េ រ៉ាយរ៉ាប់អំពីកម្មវិធីដ៏ធំដុំបំផុតទាំងឡាយ ដែលមានការឧបត្ថម្ភពីមូលនិធិ រ៉ុកឺហ្វេល្ល័រ ។

## *ការពង្រឹងការគ្រប់គ្រងផ្ទៃក្នុងរបស់មជ្ឈមណ្ឌល*

ដើម្បីបម្រើកម្មវិធីទាំងឡាយនេះ ហើយក៏មានន័យថា ជួយលើកបេសកកម្មរបស់មជ្ឈមណ្ឌល ជូនទៅស្ថាប័នដែលគ្រប់គ្រងយើង មជ្ឈមណ្ឌលបានមានភារកិច្ចពង្រឹងសមត្ថភាពប្រតិបត្តិការរបស់ខ្លួនផ្នែកចាត់ការ និងផ្នែករៀបចំ ។

យើងយល់ថា ការពង្រីកក្រុមយើងឲ្យធំទូលាយនៅក្នុងខេត្តសៀមរាប និងនៅក្រៅខេត្តសៀមរាប គឺជាការចាំបាច់មួយ ។ កាលពី ១ ឆ្នាំកន្លងទៅ មជ្ឈមណ្ឌលមានបុគ្គលិក ៥ នាក់ ធ្វើការពេញវេលា ។ ឥឡូវនេះ ចំនួនឡើងទៅដល់ ៩ នាក់ (ដោយមិនរាប់អ្នកដឹកនាំកម្មវិធី) ។ យើងបានចាត់តំណែងសំខាន់ ៗ ២ ដែលត្រូវការចំណាយពេលពេញលេញ គឺ ធនធានមនុស្ស និងប្រតិបត្តិការ ១ ហើយនិងកម្មវិធីព្រមទាំងការអភិវឌ្ឍ ១ ។ លោក ចនវីក្ស ដែលជាអ្នកជំនួយការនាយកផ្នែកធនធានមនុស្សនិងប្រតិបត្តិការ បានប្រមូលធ្វើជំនិតដៃសម្រាប់បុគ្គលិក ១ ដើម្បីសម្របសម្រួលការលូតលាស់របស់យើងទៅអនាគត ។ ទន្ទឹមនឹងនេះដែរ លោក ហ្វ្រង់ស្វា តាំងទុយរីយ៉េ អ្នកជំនួយការនាយកផ្នែកកម្មវិធីនិងអភិវឌ្ឍ កំពុងតែងគោលការណ៍ណែនាំ សម្រាប់ចាត់ចែងកម្មវិធីផ្សេង ៗ ដែល ម.ខ.ស. ធានា ហើយដែលមានចំនួនកាន់តែកើនឡើង ដើម្បីឲ្យវាមានដំណើរការយ៉ាងងាយស្រួល ។

ម.ខ.ស. ក៏បានទទួលគុណប្រយោជន៍ពីអ្នកស្ម័គ្រចិត្ត ដែលអញ្ជើញមកដល់សៀមរាប មកពីនានាប្រទេស ដើម្បីជួយបុគ្គលិកយើង ក្នុងវិស័យផ្សេង ៗ ។ ខ្ញុំសូមឆ្លៀតឱកាស ដើម្បីសូមអរគុណ ខែរីស ហ្រេស៊ីរ បារណាប៊ី ហល្ល និង ម៉ូនិក ឡឺរូ អំពីការជួយជ្រោមជ្រែងដ៏មានគុណតម្លៃរបស់គាត់នៅឆ្នាំ ២០០១ ។ យើងកំពុងរៀបកម្មវិធីអន្តេវាសិកដ្ឋាន ឲ្យមានទ្រង់ទ្រាយឡើង ។ នេះនឹងផ្ដល់នូវបទពិសោធន៍ដ៏សម្បូរសប្បាយ ដល់និស្សិតនិងបុគ្គលិក ដែលមកពីស្ថាប័នដែលរួមការងារជាមួយយើង ។ នៅក្នុងពេលជាមួយគ្នានេះដែរ វានឹងជួយឲ្យយើងពង្រីកបេសកកម្មយើងឲ្យដើរទៅឆ្ងាយទៀត ។

ការខិតខំរបស់យើង ដើម្បីពង្រីកសមត្ថភាពប្រតិបត្តិការរបស់មជ្ឈមណ្ឌល ជាការសាកល្បងធំ ១ ចំពោះអង្គការថ្មី ។ ទាំងឡាយដោយសារប្រាក់មូលនិធិភាគច្រើនដែលយើងទទួល ពាក់ព័ន្ធទៅនឹងគម្រោងការផ្ទាល់ ។ ដើម្បីបំពេញគម្រោងការអស់នេះ និងដើម្បីមានសេចក្ដីទៀងទាត់ទៅនឹងបេសកកម្មដំបូង មជ្ឈមណ្ឌលក៏នឹងទទួលគុណប្រយោជន៍ ពីចិត្តបុណ្យរបស់អ្នកឲ្យ ដែលជាឯកជន ហើយដែលយកចិត្តទុកដាក់នឹងគោលដៅវែងឆ្ងាយរបស់យើង ។ ដោយសារការអាសាស្ម័គ្រចិត្តរបស់បណ្ឌិត អូលីវីយ៉េ ប៊ែរនិញ៉េ ពីក្រុងញីវយ៉ក យើងកំពុងពង្រឹងសមត្ថភាពរៃអង្គាសប្រាក់មូលនិធិ ជាពិសេសដោយពង្រីកបណ្ដាញអ្នកធ្វើកុសលដល់យើង ។

ឆ្នាំមុននេះ អ្វី ៗ ក៏បានប្រកបដោយជោគជ័យមែនទែន ។ តែដើម្បីឲ្យយើងអាចបន្តការងារ ខ្ញុំត្រូវអង្វរម្ដងទៀត ឲ្យអស់លោកអ្នកមេត្តាជួយយើង ។ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះត្រង់របស់ខ្ញុំ ចំពោះអស់លោកអ្នក ដែលបានជួយឧបត្ថម្ភយើង ។ បើពុំបានការជួយឧបត្ថម្ភនេះ យើងមុខជាពុំបានធ្វើប្រតិបត្តិការ និងការរីកលូតលាស់យ៉ាងនេះទេ ។

## *មជ្ឈមណ្ឌលយើង ហើយនិងបណ្ដាសហគមន៍ខេមរវិទ្យា*

ខ្ញុំពុំអាចបញ្ចប់កំណត់ត្រានេះ ដោយគ្មានបានរ៉ាយរ៉ាប់អំពីការខំប្រឹងថ្មី ៗ របស់មជ្ឈមណ្ឌល ដើម្បីតាំងខ្លួនជាចំណែកមួយក្នុងបរិស្ថានវប្បធម៌និងអប់រំ ដែលធំទូលាយ ហើយដែលគ្របទាំងប្រទេសកម្ពុជានិងបរទេសនោះបានទេ ។

ការធ្វើដំណើរលោកទីព្រឹទ្ធប្រឹក្សា ដេវិឌ ឆាន់ឌ្ល័រ ទៅកាន់ប្រទេសជប៉ុន កាលពីខែសីហា ឆ្នាំ ២០០១ កន្លងមកនេះ ជារឿងមួយគួរឲ្យចាប់អារម្មណ៍ណាស់ ។ នាពេលធ្វើដំណើរនេះ លោក ដេវិឌ

បានធ្វើសិក្ខាសាលានៅសាកលវិទ្យាល័យការសិក្សាបរទេសនៅតូក្យូ ហើយលោកបានពិភាក្សាយ៉ាងល្អិតល្អន់ ជាមួយនឹងបណ្ឌិត តូម៉ូកូ អូកាដា និងបណ្ឌិត ហ៊ីរ៉ូមី អ៊ូអេដា ។ លោក ដេវិឌ ក៏មានឱកាសបាននិយាយ ពិភាក្សាអំពីអនាគតរបស់ខេមរវិទ្យា ជាមួយនឹងតំណាងក្រសួងការបរទេសជប៉ុន មូលនិធិជប៉ុន មូលនិធិតូយ៉ូតា ហើយនិងមូលនិធិសាសេកាវ៉ាផងដែរ ។ លោកក៏មានការជួបជុំក្រៅផ្លូវការ ជាមួយលោកធំមួយចំនួន ដូចជា លោកសាស្ត្រាចារ្យ យ៉ូស៊ីអាគី អ៊ីស៊ីហ្សាវ៉ា ពីសាកលវិទ្យាល័យ សូហ្វីយ៉ា និង លោកសាស្ត្រាចារ្យ យ៉ូណោអូ អ៊ិស៊ី ពីសាកលវិទ្យាល័យការសិក្សាអន្តរជាតិកាន់ដា ។ យើងសូមដឹងគុណដល់បណ្ឌិត អាឡាន់ ហ្វេស្តែន ពីមូលនិធិ តូយ៉ូតា ដែលបានជួយរៀបចំទស្សនកិច្ចរបស់លោក ដេវិឌ ។ ក្រៅពីទំនាក់ទំនង ដែលមជ្ឈមណ្ឌលយើងសង្ឃឹមនឹងមានជាមួយសាកលវិទ្យាល័យនានា នៅអាមេរិក និងអឺរ៉ុប ការចូលរួមរបស់យើងក្នុងសហគមន៍អប់រំអាស៊ី មិនសូវមានន័យអ្វីប៉ុន្មានទេ បើគ្មានទំនាក់ទំនងជិតស្និទ្ធជាមួយស្ថាប័នជប៉ុនទាំងឡាយ ដែលមានសកម្មភាពស្រាប់នៅកម្ពុជា ។

នាទីរបស់មជ្ឈមណ្ឌលយើង ក៏បានបង្កើននៅប្រទេសកម្ពុជាផ្ទាល់ ។ នៅរាជធានីភ្នំពេញ កម្មវិធីនានារបស់យើង កំពុងមានដំណើរការទៅមុខ ។ នៅសៀមរាប នៅពេលមានប្រជុំគណៈកម្មាធិការអន្តរជាតិសម្របសម្រួលដើម្បីការពារអង្គរ ខ្ញុំមានលទ្ធភាពរ៉ាយរ៉ាប់អំពីការពង្រីកលូតលាស់ និងជឿនលឿនរបស់មជ្ឈមណ្ឌលឲ្យអ្នកចូលរួមជ្រាប ។ នៅពេលជាមួយគ្នានេះដែរ យើងខ្ញុំមានកិត្តិយសបានទទួលទស្សនកិច្ចរបស់លោកសាស្ត្រាចារ្យ អាហ្សេឌីន បេស្ទាអ៊ូស្ទ ដែលជាទីប្រឹក្សាផ្នែកវប្បធម៌នៅយូណេស្កូ ។

ដូច្នេះ យើងកំពុងបញ្ចប់ឆ្នាំទី ៣ នៃសកម្មភាពយើង ដែលប្រកបដោយសេចក្តីសង្ឃឹមជាច្រើន ហើយយើងក៏សង្ឃឹមថា ការរីកលូតលាស់ដ៏អស្ចារ្យនេះ នឹងមានការបន្តទៅទៀត ។ ខ្ញុំសូមឆ្លៀតឱកាសដើម្បីថ្លែងអំណរគុណចំពោះសហគមន៍ ដែលកំពុងតែរីកចម្រើនរបស់អ្នកទាំងឡាយ ដែលបានជួយឲ្យគម្រោងនេះអាចធ្វើបាន ៕